**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:៣៨៦
ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៥
**សាលដីកា**
លេខ:២៣៣
ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក .............. ជាចៅក្រម
៤-លោក ............... ជាចៅក្រម
៥-លោក ............... ជាចៅក្រមរបាយការណ៍

**<u>ក្រឡាបញ្ជី</u>**

-លោក ...................

**<u>តំណាងមហាអយ្យការ</u>**

-ឯកឧត្តម ...............។ ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៥០(ក) ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២១៥ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះសសផ (ជាម្ចាស់បណ្តឹងសាទុក្ខ)គេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ មុខរ ធ្វើស្រែ មានទីលំនៅ ភូមិទួលរកា ឃុំកំពង់ត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ខ្ញុំពុកឈ្មោះ ដុក ខុន (រ) ម្តាយឈ្មោះអ៊ឹម ហន់ (ស) ។

និង ចុងចម្លើយឈ្មោះតតព(ជាចុងបណ្តឹងសាទុក្ខ) គេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរមានទីលំនៅ ផ្ទះលេខ១១$E_0$ ផ្លូវលេខ២៨២ សង្កាត់បឹងកេងកង ខណ្ឌចំការមន រាជធានីភ្នំពេញ ជាតំណាងឲ្យឈ្មោះ ហេង សយ ។

មានមេធាវីលោក ............ ។

**<u>កម្មវត្ថុបណ្តឹង:</u>** ប្តឹងទាមទារដីស្រែ ។

បានឃើញបណ្តឹងសាទុក្ខលេខ២៨១ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៥ របស់ឈ្មោះសសផ បាន ប្តឹមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី១៧-០៨-២០០១ របស់ដើមចោទឈ្មោះសសផ បញ្ជាក់ថា ឈ្មោះ ហេង សយ បានរំលោភយកដីរបស់ខ្លួនដែលមានប្លង់កាន់កាប់ចាប់តាំងពីឆ្នាំ១៩៩០មក ដែលមានទទឹង ៧៥ម បណ្ដោយ១០០ម តែបច្ចុប្បន្ននេះអ្នកទាំងពីរបានទាមទារក្បាលដីជាប់នឹងចំណីថ្នល់ថា ជាដីរបស់គាត់ទៀត ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ១៥៣ ចុះថ្ងៃទី០៥-១២-២០០១ របស់តុលាការខេត្តព្រៃវែង ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០១ របសំដើមចោទឈ្មោះ៖ សុខ សុជាតទូតជាត្រឹមត្រូវ

១ - ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០១ របស់ដើមចោទឈ្មោះសសផទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២ - បង្គាប់ឱ្យឈ្មោះហេង សយ ជាចុងចម្លើយបញ្ឈប់ការធ្វើស្រែលើដីទំនាស់គឺ ដីសាធារណៈ និងដីចំណីថ្នល់ ដែលមានទំហំ០៩ម៉ែត្រ គុណ ៩០.៣០ម៉ែត្រ គិតចាប់តាំងពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ តាមមាត្រា១២,១៥,១៦,៤៣,៥៨ នៃច្បាប់ភូមិបាលថ្មីដែលប្រកាសឱ្យប្រើតាមព្រះរាជក្រិត្យលេខៈ ន-ស-រកម-០៨០១-១៤ ចុះថ្ងៃទី៣០-០៨-២០០១ នៃព្រះជាណាចក្រកម្ពុជា ។

៣- ឱ្យដើមចោទថែរក្សាលើដីដែលមានទំហំ៩ម៉ែត្រ គុណ ៩០,៣០ម៉ែត្រ ដែលស្ថិតនៅចំពីមុខដីរបស់ ដើមចោទ ទុកជាទ្រព្យសម្បត្តិសាធារណៈ ។

៤- បង្គាប់ឱ្យចុងចម្លើយឈ្មោះហេង សយ បង់ប្រាក់ប្រដាប់ក្ដីគឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង ១៨០០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០៛ សរុបទាំងអស់ ៧.០០០៛ ដែលដើមចោទបានបង់ទុករួចហើយ កាលបើហួសឧទ្ធរណ៍បង្គាប់ឱ្យចុងចម្លើយសងប្រាក់៧០០០៛ ទៅឱ្យដើមចោទវិញ និង ឱ្យបង់ពន្ធសមាមាត្រ $\frac{១x១៥០ដុល្លារ}{១០០}$ ប្រាក់នេះដាក់ចូលថវិការដ្ឋ៨០ភាគរយ និង រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០ភាគរយ ។

៥- សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខគូភាគី បើភាគីណាមិនសុខចិត្តទុកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់គិតថាប់ពីពេលនេះតទៅ ។

បានឃើញ បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០១ របស់ឈ្មោះហេង សយ បានប្ដឹងមិនសុខចិត្តនឹង សាលក្រមរបស់តុលាការ ខេត្តព្រៃវែងត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៥០(ក)ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១- ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០១ របស់ឈ្មោះហេង សយ ទុកជាត្រឹមត្រូវតាមទម្រង់និង គតិច្បាប់ ។

២- បដិសេធចោលសាលក្រមរដ្ឋប្បវេណីលេខ១៥៣ ចុះថ្ងៃទី០៥-១២-២០០១ របស់តុលាការខេត្តព្រៃវែងចោលទាំងស្រុង ។

៣- ទទួលស្គាល់ការកាន់កាប់ដីរបស់ចុងចម្លើយដោយឱ្យចុងចម្លើយកាន់កាប់ដីដោយស្របច្បាប់ចាប់ពីពេលនេះតទៅ ។

៤- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០៛ ដែលចុងចម្លើយបានបង់រួចហើយ គឺ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥៥០៛ ង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើកិច្ចប្រគល់ដីជាកោះអាជ្ញាធរតុលាការ ចំនួន ១០០០០៛ សរុប១៣.០០០៛ ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២៨១ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៥ របស់ឈ្មោះសសផ បានប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញ សារណារបស់ឈ្មោះតតពចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ ។ បានឃើញ សារណាតបរបស់ឈ្មោះ តតពចុះថ្ងៃទី០១ ខែធ្នូឆ្នាំ២០០៥ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :

បណ្តឹងសាទុក្ខរបស់ឈ្មោះសសផ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា។

សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។

លោកសសផ បានឆ្លើយថា ដីនេះខ្លួនមានបង្កាន់ដៃត្រឹមត្រូវ ហើយខ្លួនបានកាន់កាប់តាំងពីឆ្នាំ១៩៧៩ មកម្ល៉េះលោកហេង សយ បានចូលមកធ្វើស្រែលើដីនេះក្រោយឪពុកខ្លួនទេ តែពេលដែលគាត់ចូលធ្វើស្រែនេះខ្លួន បានហាមឃាត់គាត់ដែរ តែគាត់មិនព្រមស្តាប់ ឈ្មោះហេង សយ បានចូលមកធ្វើស្រែលើដីទំនាស់នៅឆ្នាំ១៩៨១-៨២ ហើយក៏ទើបតែធ្វើតូបនៅលើដីទំនាស់នេះ ក្នុងឆ្នាំ២០០៤នេះទេ ចំណែកផ្ទះរបស់គាត់នៅឆ្ងាយ ពីដីនេះប្រហែល ប្រាំរយម៉ែត្រ សព្វថ្ងៃនៅលើដីនេះមានផ្ទះមួយ និងកូនតូបពីរទៀត ។ ខ្លួនសុំទាមទារយកដីនេះជាកម្មសិទ្ធិវិញព្រោះគាត់បានមករំលោភយកដីរបស់ខ្លួន។

<u>**សំណូមពរ**</u> សុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ។

លោក តតពបានឆ្លើយថា ឈ្មោះហេង សយ និងហេង ចាន់ធី បានចូលមកកាន់ដីនេះតាំងពីឆ្នាំ១៩៧៩ រហូតមកដល់សព្វថ្ងៃ ដោយបានដាក់ពាក្យសុំកាន់កាប់ត្រឹមត្រូវដែលមានទំហំ៩មx៩០.៣០ម ។

ដីនេះដើមឡើយជាដីព្រៃសុទ្ធសាធ លោកហេង សយ បានកាប់ឆ្ការព្រៃធ្វើស្រែដោយបានទទួលស្គាល់ពី អាជ្ញាធរមូលដ្ឋានទាំងអស់ ។ នៅឆ្នាំ២០០១ ឈ្មោះសសផ ដែលមានដីនៅខាងក្រោយដីរបស់

ហេង ចាន់ធី បានមកសុំទិញពីឈ្មោះហេង ចាន់ធី ឱ្យតម្លៃមួយរយហាសិបដុល្លា តែត្រូវបានឪពុករបស់ហេង ចាន់ធី មិនព្រមលក់ឱ្យឈ្មោះសសផ ទេ ទើបឈ្មោះសសផ ដាក់ពាក្យប្តឹងទាមទារដីនៅតែម្តង ។ ដីនេះខ្លួនសុំទាមទារយកទាំងអស់ ។

មេធាវីលោកពេជ្រ គន្ធារី ការពារឱ្យលោកតតពបានធ្វើសេចក្តីសន្និដ្ឋានថាៈ ប្លង់ដីដែលលោកសុខ សូផាត បានលើកមកបង្ហាញជូនមុននេះមានលក្ខណៈខុសពីទីតាំងដីទំនាស់ទាំងអស់ដូច្នេះលោកសសផ មិនបានដឹងច្បាស់អំពីដីរបស់ខ្លួនពិតប្រាកដឡើយ ។ តាមពិតលោកសសផ មានដីនៅខាង ក្រោយដីរបស់កូនក្តីខ្លួនទេ គឺនៅឆ្នាំ២០០១ គាត់បានមកសុំទិញដីនេះពីកូក្តីរបស់ខ្លួនមិនបានគាត់ក៏ដាក់ពាក្យប្តឹងទាមទារ យកដីនេះតែម្តង ។ ដីទំនាស់នេះកូនក្តីរបស់ខ្លួនកំពុងតែកាន់កាប់ហើយស្នាក់នៅរហូតមកដល់សព្វថ្ងៃ ដែលស្របតាមច្បាប់ភូមិបាលត្រង់មាត្រា៣០ និង៣៨ហើយ ។

**<u>សំណូមពរ</u>** សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអាយុការ

- ក្រោយពីបានស្តាប់មធ្យោបាយដោះសរបស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីក្នុងចម្លើយ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

យល់ឃើញថាៈ បណ្តឹងសាទុក្ខលេខៈ២៨១ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៥ របស់លោកសសផ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះ បានដោយយោងតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី។

យល់ឃើញថាៈ ការដែលសាលាឧទ្ធរណ៍សម្រេចប្រគល់សិទ្ធិលើដីទំនាស់ឱ្យទៅចុងចម្លើយនោះគឺ ជាការត្រឹមត្រូវហើយប៉ុន្តែសាលាឧទ្ធរណ៍មានកំហុសដោយមិនបានកំណត់អំពីទំហំ និងទីតាំងនៃដីទំនាស់ឱ្យបានច្បាស់លាស់នៅឡើយ ដែលអាចនាំឱ្យមានភាពមិនច្បាស់លាស់ក្នុងការអនុវត្តន៍ ។

យល់ឃើញថាៈ សាលដីការដ្ឋប្បវេណីលេខ៥០(ក)ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទម្រង់ ទាំងគតិច្បាប់ ។

### ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១ -ទទួលបណ្តឹងសាទុក្ខលេខៈ២៨១ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៥ របស់ឈ្មោះសសផ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២ -ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខៈ៥០(ក) ចុះថ្ងៃទី២៧ ខែក្កដា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ពេញទាំងមូល ។

៣ -បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៣៨៦ ចុះថ្ងៃទី២៣-០៨-២០០៥ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩០០០៛ ដែលចុងចម្លើយ បានបង់ គឺៈ

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤,០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

- ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប ១៩០០០៛ ។

៥ -សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ ។